ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Mathematical Intelligence



Series 01

វិញ្ញាសាគណិតវិទ្យាសម្រាប់ស្រាវជ្រាវ

ថ្នាក់ទី៖ ១០ ១១ និង ១២

*សម្រាប់៖ * សិស្សពូកែ និង ត្រៀមប្រលងជំនាញផ្សេងៗ*

** ត្រៀមប្រលងអាហារូបករណ៍បរទេស*

ដកស្រង់ចេញពីឯកសារ អង់គ្លេស បារាំង និង វៀតណាម

 ២០១. ផុល កើន

អារម្ភកថា

សៀវភៅ **វិញ្ញាសា គណិតវិទ្យាសម្រាប់ស្រាវជ្រាវ** គឺជាវណ្ណកម្មទី១នៃ “Mathematical Intelligence Series” ត្រូវបានរៀបចំឡើងក្នុងគោលបំនង ជួយពង្រឹងសមត្ថភាព ប្អូនៗ ដែលកំពុងសិក្សា នៅកម្រិតវិទ្យាល័យ។ ជាពិសេសប្អូនៗ ដែលមានបំណងប្រលងអាហារូបករណ៍ទៅសិក្សានៅបរទេស។

សៀវភៅនេះត្រូវបានចែកជាពីរផ្នែកដែល ផ្នែកទី១ រៀបចំឡើងជាភាសាខ្មែរ និងផ្នែកទី២ ជាភាសាអង់គ្លេស។ ដោយសារការប្រលងអាហារូបករណ៍ទៅសិក្សានៅបរទេស ជាពិសេសប្រទេសជឿនលឿន ដូចជា ជប៉ុន សឹង្ហបូរី ត្រូវបានជម្រុះ ជាច្រើនដំណាក់កាល គឺ ជម្រុះជាភាសាខ្មែរ រួចទើបជម្រុះជាភាសាអង់គ្លេស ទើបសៀវភៅនេះត្រូវបានបញ្ចូលលំហាត់ ជាភាសាអង់គ្លេស ក្នុងគោលបំណងសម្រួលដល់ប្អូនៗ នៅតាមបណ្តាខេត្តដែលពិបាករកឯកសារជាភាសាអង់គ្លេស ។ លំហាត់មួយចំនួនធំនៅក្នុងសៀវភៅនេះ សុទ្ធសឹងតែជាលំហាត់ដែលដកស្រង់ពីវិញ្ញាសាធ្លាប់ប្រលងនៅបរទេស។

ទោះបីជាសៀវភៅនេះត្រូវបានពិនិត្យជាច្រើនសារក៏ដោយ ក៏មិនអាចជៀសវាងនូវកំហុសឆ្គងដោយអចេតនាបានឡើយ។ យើងខ្ញុំនឹងរងចាំទទួលនូវមតិរិះគន់ ស្ថាបនាដោយក្តីរីករាយ ដើម្បីអោយសៀវភៅនេះកាន់តែមានភាពសុក្រិត។

វិញ្ញាសាទី១

១. គេអោយ x, y ជាចំនួនពិតដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ៖
$(x+5)^2+(y-12)^2=14^2$ ។ ចូរគណនាតំលៃអប្បបរមានៃ
x^2+y^2 ។

២. គេអោយអនុគមន៍ $f(x)$ កំនត់លើ $\mathbb{R}$ ហើយផ្ទៀងផ្ទាត់
$f(1)=1$ ។ចំពោះគ្រប់តំលៃ $x\in\mathbb{R}$; $f(x+5)\geq f(x)+5$ និង
$f(x+1)\leq f(x)+1$ ។ បើ $g(x)=f(x)+1-x$ ។ គណនា
$g(2011)$ ។

៣. តាង $\log_4(x+2y)+\log_4(x-2y)=1$ ។ គណនាតំលៃអប្បបរមានៃ $|x|-|y|$ ។

៤. គណនាអាំងតេក្រាល៖

ក. $I=\int\frac{dx}{x^2+2x-3}$ ខ. $J=\int\frac{dx}{x^2-6x+10}$

គ. $K=\int\frac{dx}{2x^2+8x+2}$ ។

៥. កំនត់តំលៃ $a<0$ ដើម្បីអោយវិសមភាព $(*)$ ផ្ទៀងផ្ទាត់ចំ ពោះគ្រប់តំលៃ $x\in\mathbb{R}$

$$\sin^2 x+a\cos x+a^2\geq 1+\cos x \qquad (*)$$

៦. គេមានត្រីកោណ ABC ។ បង្ហាញថា
$A=2B \Leftrightarrow a^2=b(b+c)$

សម្រាយបញ្ជាក់

១. តាង $x+5=14\cdot\cos\theta$ និង $y-12=14\cdot\sin\theta$ ចំពោះ
$\theta\in[0,2\pi[$

គេបាន $x^2+y^2=(14\cdot\cos\theta-5)^2+(14\cdot\sin\theta+12)^2$

$=196\cdot\cos^2\theta-140\cdot\cos\theta+25+196\cdot\sin^2\theta+336\cdot\sin\theta+144$

$=196\cdot(\cos^2\theta+\sin^2\theta)+28(12\cdot\sin\theta-5\cdot\cos\theta)+169$

$=365+28(12\cdot\sin\theta-5\cdot\cos\theta)$

$$=365+28\cdot 13\left(\frac{12}{13}\cdot\sin\theta-\frac{5}{13}\cdot\cos\theta\right)$$

ដោយ $\left(\frac{12}{13}\right)^2+\left(\frac{5}{13}\right)^2=1$ តាង $\cos\varphi=\frac{12}{13};\ \sin\varphi=\frac{5}{13}$

$\Rightarrow x^2+y^2=365+364(\sin\theta\cos\varphi-\sin\varphi\cos\theta)$

$=365+364\cdot\sin(\theta-\varphi)$

ដោយ $-1\le\sin(\theta-\varphi)\le 1$

នាំអោយ $x^2+y^2\ge 365-364\cdot 1=1$

យើងបាន x^2+y^2 មានតំលៃអប្បបរមាស្មើ 1 ពេលដែល

$$\sin(\theta-\varphi)=-1\Leftrightarrow\theta-\varphi=\frac{3\pi}{2}\Leftrightarrow\theta=\frac{3\pi}{2}+\arctan\frac{5}{12}$$

<u>ដូចនេះ</u> x^2+y^2 មានតំលៃអប្បបរមាស្មើ 1

២. យើងមាន $f(x)+5\le f(x+5)\le f(x+4)+1\le$
$f(x+3)+2\le f(x+2)+3\le f(x+1)+4\le f(x)+5$
នាំអោយ វិសមភាព $f(x+5)\ge f(x)+5$ និង
$f(x+1)\le f(x)+1$ក្លាយជាសមភាពចំពោះគ្រប់តំលៃ $x\in\mathbb{R}$
យើងបាន $f(x+1)=f(x)+1$
ដោយ $f(1)=1,\quad f(2)=f(1)+1=1+1=2,$
$f(3)=f(2)+1=2+1=3,\dots,$
$f(2011)=f(2010)+1=2010+1=2011$
នាំអោយ
$g(2011)=f(2011)+1-2011=2011+1-2011=1$
<u>ដូចនេះ</u> $\quad g(2011)=1$

៣. យើងមាន $\log_4(x+2y)+\log_4(x-2y)=1$
$\Leftrightarrow \log_4\left[(x+2y)(x-2y)\right]=1$

នាំអោយ $\begin{cases} x+2y>0 \\ x-2y>0 \\ (x-2y)(x+2y)=4 \end{cases}$

យើងបាន

$$\begin{cases} x>2|y|\ge 0 \\ x^2-4y^2=4 \end{cases}$$

តាមរយៈភាពស៊ីមេទ្រីនៃតំលៃ y ធៀបនឹងសូន្យ (មានន័យថា y អាចជាចំនួនវិជ្ជមាន ឬ អវិជ្ជមានដែលមាន 0 ជាចំនុចឆ្លុះ) នោះ

យើងសិក្សាតែក្នុងករណី $y \geq 0$ គឺគ្រប់គ្រាន់ហើយ។
ម្យ៉ាងទៀត $x > 0$
នាំអោយ $|x| - |y| = x - y$ ជាចំនួនពិតវិជ្ជមាន
យក $u = x - y \Rightarrow x = u + y$ ជំនួសក្នុង $x^2 - 4y^2 = 4$

$$\Rightarrow (u+y)^2 - 4y^2 = 4$$

$$\Rightarrow u^2 + 2uy + y^2 - 4y^2 = 4$$

$$\Rightarrow 3y^2 - 2uy + 4 - u^2 = 0 \qquad y \text{ ជាអថេរពិត}$$

$$\Delta' = u^2 - 12 + 3u^2 = 4u^2 - 12 \geq 0$$

នាំអោយ $u \geq \sqrt{3}$ ឬ $u \leq -\sqrt{3}$ តែ u វិជ្ជមាន
នាំអោយ $u \geq \sqrt{3}$

សញ្ញាស្មើកើតមានពេលដែល $x = \dfrac{4\sqrt{3}}{3}; y = \dfrac{\sqrt{3}}{3}$

<u>ដូចនេះ</u> តំលៃតូចបំផុតនៃ $|x| - |y|$ គឺ $\sqrt{3}$

៤. គណនាអាំងតេក្រាលខាងក្រោម៖

ក. $\displaystyle\int \frac{dx}{x^2 + 2x - 3} = \int \frac{dx}{(x-1)(x+3)}$

យក $\displaystyle\frac{1}{(x-1)(x+3)} = \frac{A}{x-1} + \frac{B}{x+3} = \frac{Ax + 3A + Bx - B}{(x-1)(x+3)}$

$$= \frac{(A+B)x + (3A-B)}{(x-1)(x+3)}$$

ដើម្បីអោយសមភាពផ្ទៀងផ្ទាត់ចំពោះគ្រប់តំលៃ $x \in \mathbb{R}$

លុះត្រាតែ $A+B=0$ និង $3A-B=1$

នាំអោយ $A=\frac{1}{4}$ និង $B=-\frac{1}{4}$

$$\Rightarrow \int \frac{dx}{x^2+2x-3} = \int \left(\frac{1/4}{x-1} + \frac{-1/4}{x+3} \right) dx = \frac{1}{4}\int \frac{dx}{x-1} - \frac{1}{4}\int \frac{dx}{x+3}$$

$$= \frac{1}{4}\ln|x-1| - \frac{1}{4}\ln|x+3| + C$$ C ជាចំនួនពិតថេរ

<u>ដូចនេះ</u> $\int \frac{dx}{x^2+2x-3} = \frac{1}{4}\ln|x-1| - \frac{1}{4}\ln|x+3| + C,\ C\in\mathbb{R}$

ខ. $\int \frac{dx}{x^2-6x+10} = \int \frac{dx}{(x^2-6x+9)+1} = \int \frac{dx}{(x-3)^2+1}$

តាង $u=x-3 \Rightarrow du=dx$

$$\Rightarrow \int \frac{dx}{x^2-6x+10} = \int \frac{du}{u^2+1^2} = \arctan u + C$$

$$= \arctan(x-3) + C$$ C ជាចំនួនពិតថេរ

<u>ដូចនេះ</u> $\int \frac{dx}{x^2-6x+10} = \arctan(x-3) + C$

គ. $\int \frac{dx}{2x^2+8x+2} = \int \frac{dx}{2(x^2+4x+1)} = \frac{1}{2}\int \frac{dx}{(x+2)^2-\sqrt{3}^2}$

តាង $u=x+2 \Rightarrow du=dx$

$$\Rightarrow \int \frac{dx}{2x^2+8x+2} = \frac{1}{2}\int \frac{du}{u^2-\sqrt{3}^2} = \frac{1}{4\sqrt{3}}\ln\left|\frac{u-\sqrt{3}}{u+\sqrt{3}}\right| + C$$

$$=\frac{1}{4\sqrt{3}}\ln\left|\frac{x+2-\sqrt{3}}{x+2+\sqrt{3}}\right|+C \qquad C \text{ ជាចំនួនពិតថេរ}$$

<u>ដូចនេះ</u> $\int\frac{dx}{2x^2+8x+2}=\frac{1}{4\sqrt{3}}\ln\left|\frac{x+2-\sqrt{3}}{x+2+\sqrt{3}}\right|+C$ ដែល $C\in\mathbb{R}$

៥. កំនត់តំលៃអវិជ្ជមាន a

យើងមាន $\sin^2 x+a\cos x+a^2\geq 1+\cos x$

ករណី $x=0 \quad \Rightarrow a^2+a\geq 2$

$$\Rightarrow a^2+a-2\geq 0$$
$$\Rightarrow (a-1)(a+2)\geq 0$$
$$\Rightarrow a\in\left]-\infty,-2\right[\cup\left]1,+\infty\right[$$

ដោយ $a<0 \quad \Rightarrow a\in\left]-\infty,-2\right[$

ចំពោះ $a\in\left]-\infty,-2\right[$ យើងបាន

$$a^2+a\cos x\geq a^2+a\geq 2\geq\cos^2 x+\cos x=1+\cos x-\sin^2 x$$

$\Rightarrow\sin^2 x+a\cos x+a^2\geq 1+\cos x$ ចំពោះគ្រប់តំលៃ $x\in\mathbb{R}$

<u>ដូចនេះ</u> $a\in\left]-\infty,-2\right[$

៦. បង្ហាញថា $A=2B\Leftrightarrow a^2=b(b+c)$

- ករណីទី១. បង្ហាញថា $A=2B\Rightarrow a^2=b(b+c)$

យើងមាន $A=2B$ និង $A+B+C=\pi$

$\Rightarrow C=\pi-3B \quad \Rightarrow\sin C=\sin(\pi-3B)=\sin 3B$

តាមទ្រឹស្តីបទស៊ីនុស យើងបាន

$$\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}=\frac{b+c}{\sin B+\sin C}$$

$$\Rightarrow \frac{a}{\sin A}=\frac{b}{\sin B}=\frac{b+c}{\sin B+\sin 3B}$$

$$\Rightarrow \frac{a^2}{\sin^2 A}=\frac{b(b+c)}{\sin B(\sin B+\sin 3B)} \qquad (*)$$

ដោយ $\sin B(\sin B+\sin 3B)=\sin B(2\sin 2B\cos B)$

$$=2\sin B\cos B\sin 2B$$
$$=(\sin 2B)(\sin 2B)=\sin^2 2B$$

តាម $(*)$ យើងបាន $\frac{a^2}{\sin^2 2B}=\frac{b(b+c)}{\sin^2 2B}$

នាំអោយ $a^2=b(b+c)$ ពិត

- ករណីទី២. បង្ហាញថា $a^2=b(b+c)\Rightarrow A=2B$

តាមទ្រឹស្តីបទស៊ីនុស $\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}$

$$\Rightarrow \frac{a^2}{\sin^2 A}=\frac{b^2}{\sin^2 B}=\frac{bc}{\sin B\sin C}=\frac{b^2+bc}{\sin^2 B+\sin B\sin C}$$

$$\Rightarrow \frac{a^2}{\sin^2 A}=\frac{b(b+c)}{\sin^2 B+\sin B\sin C}$$

ដោយ $a^2=b(b+c)$

យើងបាន $\sin^2 A=\sin^2 B+\sin B\sin C$

$$\Rightarrow \sin^2 A-\sin^2 B=\sin B\sin(A+B)$$

$$\Rightarrow (\sin A-\sin B)(\sin A+\sin B)=\sin B\sin(A+B)$$

$$\Rightarrow 4\sin\frac{A-B}{2}\cos\frac{A+B}{2}\sin\frac{A+B}{2}\cos\frac{A-B}{2}$$

$$=2\sin B\sin\frac{A+B}{2}\cos\frac{A+B}{2}$$

$$\Rightarrow 2\cos\frac{A-B}{2}\sin\frac{A-B}{2}=\sin B$$

$\Rightarrow \sin(A-B)=\sin B$ ដោយ $A-B<\pi$

យើងបាន $A-B=B$ ឬ $A-B=\pi-B$

នាំអោយ $\left[\begin{array}{l} A=2B \\ A=\pi \end{array}\right.$ យក / មិនយក ព្រោះ $A<\pi$

នាំអោយ $A=2B$

ដូចនេះ $A=2B\Leftrightarrow a^2=b(b+c)$

វិញ្ញាសាទី២

១. គណនាអាំងតេក្រាលខាងក្រោម៖

ក. $\int \frac{(2x+3)dx}{x^2+3x+4}$ ខ. $\int \frac{dx}{\sqrt{x^2-4x+3}}$

២. គេអោយពហុធាដឺក្រេទី 2 $f(x)=ax^2+bx+c$ ដែល $(a,b,c\in\mathbb{R};a\neq 0)$ ផ្ទៀងផ្ទាត់លក្ខខណ្ឌខាងក្រោម៖

$i.$ ចំពោះ $x\in\mathbb{R},\quad f(x-4)=f(2-x)$ និង $f(x)\geq x$

$ii.$ ចំពោះ $x\in]0,2[;\quad f(x)\leq\left(\frac{x+1}{2}\right)^2$

$iii.$ តំលៃតូចបំផុតនៃ f លើ $\mathbb{R}$ ស្មើ 0

កំនត់តំលៃធំបំផុតនៃ m ដែល $(m>1)$ ដើម្បីអោយ $\exists t\in\mathbb{R};$ $f(x+t)\leq x$ ចំពោះ $x\in[1,m]$

៣. កំនត់ចំនួនគត់ធម្មជាតិ n ដើម្បីអោយ $20n+2$ ចែកដាច់ $2003n+2002$

៤. រកគ្រប់ចំនួនពិត k ដែលនាំអោយវិសមភាព $a^3+b^3+c^3+d^3+1\geq k(a+b+c+d)$ ពិតចំពោះគ្រប់តំលៃ $a,b,c,d\in[-1,+\infty[$

៥. គេអោយ $\{a_n\}$ ជាស្វ៊ីតចំនួនពិត ដែល $a_1=2$ និង

$a_{n+1} = {a_n}^2 - a_n + 1$ ចំពោះ $n \in \mathbb{N}^*$ ។

បង្ហាញថា $\dfrac{1}{a_1} + \dfrac{1}{a_2} + \dfrac{1}{a_3} + \cdots + \dfrac{1}{a_{2011}} < 1$

៦. រកបណ្តាចំនួនគត់ធម្មជាតិ n ដើម្បីអោយ $n^4 - 4n^3 + 22n^2 - 36n + 18$ ជាការេប្រាកដ ។

<u>សម្រាយបញ្ជាក់</u>

១. គណនាអាំងតេក្រាល៖

ក. $\displaystyle\int \frac{(2x+3)dx}{x^2+3x+4} = \int \frac{(x^2+3x+4)'}{x^2+3x+4}dx = \ln\left|x^2+3x+4\right| + C$

ដែល C ជាចំនួនពិតថេរ

<u>ដូចនេះ</u> $\displaystyle\int \frac{2x+3}{x^2+3x+4}dx = \ln\left|x^2+3x+4\right| + C$

ខ. $\displaystyle\int \frac{dx}{\sqrt{x^2-4x+3}} = \int \frac{dx}{\sqrt{(x-2)^2-1}}$

តាង $u = x-2 \quad \Rightarrow du = dx$

នាំអោយ $\displaystyle\int \frac{dx}{\sqrt{x^2-4x+3}} = \int \frac{du}{\sqrt{u^2-1}} = \ln\left|u+\sqrt{u^2-1}\right| + C$

$= \ln\left|x-2+\sqrt{x^2-4x+3}\right| + C$ ដែល C ជាចំនួនពិតថេរ

<u>ដូចនេះ</u> $\displaystyle\int \frac{dx}{\sqrt{x^2-4x+3}} = \ln\left|x-2+\sqrt{x^2-4x+3}\right| + C$

២. កំនត់តំលៃអតិបរមានៃ m

ដោយ $f(x-4)=f(2-x)$ ចំពោះគ្រប់តំលៃ $x\in\mathbb{R}$

យើងបាន បន្ទាត់ $x=-1$ ជាអ័ក្សឆ្លុះនៃអនុគមន៍ f

តាម (iii) នោះ f បែរភាពផតឡើងលើ $\Rightarrow a>0$

នាំអោយ $f(x)=a(x+1)^2$ ដែល $a>0$ $(*)$

តាម (i) $\Rightarrow f(1)\geq 1$

(ii) $\Rightarrow f(1)\leq\left(\dfrac{1+1}{2}\right)^2=1$

យើងបាន $f(1)=1$

តាម $(*)$ $\Rightarrow 1=a(1+1)^2 \Rightarrow a=\dfrac{1}{4}$

នាំអោយ $f(x)=\dfrac{1}{4}(x+1)^2$

ដោយក្រាបនៃអនុគមន៍ $f(x)=\dfrac{1}{4}(x+1)^2$ បែរភាពផតឡើងលើ និង ក្រាបនៃ $y=f(x+t)$ បានមកដោយការបំលែងក្រាបនៃ $f(x)$ ចំនួន t ឯកតា។ ប្រសិនបើយើងចង់បានក្រាបនៃអនុគមន៍ $f(x+t)$ ស្ថិតនៅខាងក្រោមបន្ទាត់ពុះទីមួយ $y=x$ ចំពោះតំលៃ $x\in[1,m]$ ហើយ m អតិបរមា លុះត្រាតែ 1 និង m ជាឫសពីរនៃសមីការអញ្ញាតិ x

$$\frac{1}{4}(x+t+1)^2=x \qquad (**)$$

ជំនួស $x=1$ ចូលក្នុងសមីការ$(**)$ យើងបាន $t=0$ ឬ $t=-4$

- ករណី $t=0$ នោះ $(**)$មានឬស $x_1=x_2=1$ មិនយក$m>1$
- ករណី $t=-4$ នោះ $(**)$ មានឬស $x_1=1$ ឬ $x_2=9$

នាំអោយ $m=9$

ម្យ៉ាងទៀត ពេល $t=-4$ ចំពោះ $x\in[1,9]$

$$\Leftrightarrow(x-1)(x-9)\le 0$$

$$\Leftrightarrow x^2-10x+9\le 0$$

$$\Leftrightarrow x^2-9x+9\le x$$

$$\Leftrightarrow \frac{1}{4}(x+1-4)^2\le x$$

$$\Leftrightarrow f(x-4)\le x \qquad \text{ពិត}$$

<u>ដូចនេះ</u> តំលៃអតិបរមានៃm គឺ $m=9$

៣. កំនត់ចំនួនគត់ធម្មជាតិ n

ឧបមាថា $20n+2$ ចែកដាច់ $2003n+2002$

យើងបាន n ត្រូវតែជាចំនួនគូ ព្រោះ $20n+2$ ជាចំនួនគូចំពោះគ្រប់តំលៃ $n\in\mathbb{N}$ ។ ប៉ុន្តែ $2003n+2002$ គូតែក្នុងករណី n ជាចំនួនគត់គូតែប៉ុណ្ណោះ។

តាង $n=2m$ ចំពោះ $m\in\mathbb{N}^*$

គេបាន $20\times 2m+2$ ចែកដាច់ $2003\times 2m+2002$

$\Rightarrow 40m+2$ ចែកដាច់ $4006m+2002$

$\Rightarrow 20m+1$ ចែកដាច់ $2003m+1001$

ដោយ $2003m+1001=100(20m+1)+3m+901$

នាំអោយ $20m+1$ ចែកដាច់ $3m+901$

យើងបាន $k=\dfrac{3m+901}{20m+1}\in\mathbb{N}$

ករណី $k=1 \quad \Rightarrow 3m+901=20m+1 \quad \Rightarrow m=\dfrac{900}{17}\notin\mathbb{N}$

ករណី $k=2 \quad \Rightarrow 3m+901=40m+2 \quad \Rightarrow m=\dfrac{899}{37}\notin\mathbb{N}$

ករណី $k=3 \quad \Rightarrow 3m+901=60m+3 \quad \Rightarrow m=\dfrac{898}{57}\notin\mathbb{N}$

ករណី $k=4 \quad \Rightarrow 3m+901=80m+4 \quad \Rightarrow m=\dfrac{897}{77}\notin\mathbb{N}$

នាំអោយ $k\geq 5 \quad \Leftrightarrow \dfrac{3m+901}{20m+1}\geq 5$

$$\Leftrightarrow 3m+901\geq 100m+5$$
$$\Leftrightarrow 97m\leq 896$$
$$\Leftrightarrow m\leq\frac{896}{97}<10$$

យើងបាន $m=\{1,2,3,4,5,6,7,8,9\}$

ករណី $m=1 \quad \Rightarrow n=2 \quad \Rightarrow 42$ ចែកដាច់ 6008 មិនពិត

ករណី $m=2 \quad \Rightarrow n=4 \quad \Rightarrow 82$ ចែកដាច់ 10014 មិនពិត

ករណី $m=3 \quad \Rightarrow n=6 \quad \Rightarrow 122$ ចែកដាច់ 14020 មិនពិត

ករណី $m=4 \quad \Rightarrow n=8 \quad \Rightarrow 162$ ចែកដាច់ 18026 មិនពិត

ករណី $m=5 \quad \Rightarrow n=10 \quad \Rightarrow 202$ ចែកដាច់ 22032 មិនពិត

ករណី $m=6 \quad \Rightarrow n=12 \quad \Rightarrow 242$ ចែកដាច់ 26038 មិនពិត

ករណី $m=7 \quad \Rightarrow n=14 \quad \Rightarrow 282$ ចែកដាច់ 30044 មិនពិត

ករណី $m=8 \Rightarrow n=16 \Rightarrow 322$ចែកដាច់ 34050 មិនពិត

ករណី $m=9 \Rightarrow n=18 \Rightarrow 362$ចែកដាច់ 38056មិនពិត

ដូចនេះ គ្មានចំនួនគត់ធម្មជាតិ n ទេ

៩. រកគ្រប់ចំនួនពិត k

យើងមាន $a^3+b^3+c^3+d^3+1\geq k(a+b+c+d)$

ករណី $a=b=c=d=-1 \Rightarrow -3\geq k(-4) \Rightarrow k\geq \frac{3}{4}$

ករណី $a=b=c=d=\frac{1}{2} \Rightarrow 4\cdot\frac{1}{8}+1\geq 2k \Rightarrow k\leq\frac{3}{4}$

យើងបាន $k=\frac{3}{4}$

យើងនឹងបង្ហាញថា $a^3+b^3+c^3+d^3+1\geq \frac{3}{4}(a+b+c+d)$

ផ្ទៀងផ្ទាត់ចំពោះគ្រប់តំលៃ $a,b,c,d\in[-1,+\infty[$

យើងត្រូវបង្ហាញថា$4x^3+1\geq 3x$ ចំពោះគ្រប់តំលៃ $x\in[-1,+\infty)$

ឧបមាថា $4x^3+1\geq 3x \Leftrightarrow 4x^3-3x+1\geq 0$

$\Leftrightarrow 4x^3+4x^2-4x^2-4x+x+1\geq 0$

$\Leftrightarrow (x+1)(4x^2-4x+1)\geq 0$

$\Leftrightarrow (x+1)(2x-1)^2\geq 0$ ពិត ចំពោះគ្រប់តំលៃ $x\in[-1,+\infty)$

នាំអោយ ចំពោះគ្រប់តំលៃ $a,b,c,d\in[-1,+\infty[$

យើងបាន $4a^3+1\geq 3a,\ 4b^3+1\geq 3b,\ 4c^3+1\geq 3c$ និង

$4d^3+1\geq 3d$

ដោយធ្វើប្រមាណវិធីបូកអង្គនឹងអង្គនៃវិសមភាពទាំងបួន

យើងបាន $4\left(a^3+b^3+c^3+d^3+1\right)\geq 3\left(a+b+c+d\right)$

$\Rightarrow a^3+b^3+c^3+d^3+1\geq \frac{3}{4}\left(a+b+c+d\right)$ ពិត

ដូចនេះ: $k=\frac{3}{4}$

៥. បង្ហាញថា $\frac{1}{a_1}+\frac{1}{a_2}+\frac{1}{a_3}+\cdots+\frac{1}{a_{2011}}<1$

យើងមាន $a_{n+1}=a_n{}^2-a_n+1 \Rightarrow a_{n+1}-1=a_n\left(a_n-1\right)$

$$\Rightarrow \frac{1}{a_{n+1}-1}=\frac{1}{a_n\left(a_n-1\right)}=\frac{1}{a_n-1}-\frac{1}{a_n}$$

បើ $n=1 \quad \Rightarrow \frac{1}{a_2-1}=\frac{1}{a_1-1}-\frac{1}{a_1} \qquad (1)$

បើ $n=2 \quad \Rightarrow \frac{1}{a_3-1}=\frac{1}{a_2-1}-\frac{1}{a_2} \qquad (2)$

....

....

បើ $n=2011 \Rightarrow \frac{1}{a_{2012}-1}=\frac{1}{a_{2011}-1}-\frac{1}{a_{2011}} \qquad (2011)$

យក $(1)+(2)+\cdots+(2011)$ យើងបាន

$$\frac{1}{a_1}+\frac{1}{a_2}+\frac{1}{a_3}+\cdots+\frac{1}{a_{2011}}=\frac{1}{a_1-1}-\frac{1}{a_{2012}-1}=1-\frac{1}{a_{2012}-1}$$

ដោយ $a_{n+1}-a_n=a_n^2-2a_n+1=(a_n-1)^2\geq 0$ នោះ $\{a_n\}$ ជាស្វីតម៉ូណូតូនកើន ហើយ $a_1=2$ នាំអោយ $a_{2012}>1$

<u>ដូចនេះ</u> $\frac{1}{a_1}+\frac{1}{a_2}+\frac{1}{a_3}+\cdots+\frac{1}{a_{2011}}<1$

៦. កំនត់ចំនួនគត់ធម្មជាតិ n

យើងមាន $A=n^4-4n^3+22n^2-36n+18$

$=n^4-4n^3+4n^2+18n^2-36n+18=(n^2-2n)^2+18(n^2-2n)+18$

$=\left[(n^2-2n)+9\right]^2-63$

តាង $x=n^2-2n;\quad A=y^2$ ដែល y ជាចំនួនគត់មិនអវិជ្ជមាន

យើងបាន $(x+9)^2-y^2=63$

$\Rightarrow(x-y+9)(x+y+9)=63=1\times 63=3\times 21=7\times 9$

$\Rightarrow((x-y+9),(x+y+9))=\{(1,63),(3,21),(7,9)\}$

- ករណីទី១. $\begin{cases}x-y+9=1\\x+y+9=63\end{cases}$

យើងបាន $x=23$ និង $y=31$

បើ $x=23$ នាំអោយ $n^2-2n=23\Leftrightarrow n^2-2n-23=0$

$\Delta'=1+23=24\quad\Rightarrow n=1\pm\sqrt{24}$ មិនយក ព្រោះ n ជាចំនួនគត់ធម្មជាតិ

- ករណីទី២. $\begin{cases}x-y+9=3\\x+y+9=21\end{cases}$

នាំអោយ $x=3$ និង $y=9$

បើ $x=3$ $\Rightarrow n^2-2n-3=0$

យើងបាន $\left[\begin{array}{ll} n=-1 & \text{មិនយក} \\ n=3 & \text{យក} \end{array}\right.$

- ករណីទី៣. $\begin{cases} x-y+9=7 \\ x+y+9=9 \end{cases}$

នាំអោយ $x=-1$ និង $y=1$

បើ $x=-1$ $\Rightarrow n^2-2n+1=0$ $\Rightarrow n=1$

ដូចនេះ $n=1$ ឬ $n=3$

វិញ្ញាសាទី៣

១. កំនត់ចំនួនគត់ធម្មជាតិ n ដែលបណ្តាលអោយ A ជាការេប្រាកដ។ $A = n^4 + 6n^3 + 11n^2 + 3n + 31$

២. គេអោយ x, y ជាចំនួនពិតវិជ្ជមានផ្ទៀងផ្ទាត់ $x^3 + y^3 = x - y$ ។ បង្ហាញថា $x^2 + 4y^2 < 1$

៣. ចំពោះ u, v, w ជាចំនួនពិតវិជ្ជមានផ្ទៀងផ្ទាត់លក្ខខណ្ឌ៖ $u\sqrt{vw} + v\sqrt{wu} + w\sqrt{uv} \geq 1$ ។ កំនត់តំលៃអប្បបរមានៃចំនួនពិតថេរ λ ដើម្បីអោយ $u + v + w \geq \lambda$ ។

៤. គណនាអាំងតេក្រាលខាងក្រោម៖

ក. $I = \int \frac{4x^2 + 8x + 7}{x^2 + 6x + 10} dx$

ខ. $J = \int \frac{2x^3 - 5x^2 + 6x + 2}{x^2 - x - 1} dx$

៥. គេអោយ a, b, c ជាចំនួនពិតវិជ្ជមាន។ កំនត់តំលៃអប្បបរមានៃ

$$A = \frac{a + 3c}{a + 2b + c} + \frac{4b}{a + b + 2c} - \frac{8c}{a + b + 3c}$$ ។

៦. គេអោយ $f : \mathbb{R} \to \mathbb{R}$ ជាអនុគមន៍ដែល $f(0) = 1$ ។ ចំពោះគ្រប់តំលៃ $x, y \in \mathbb{R}$; $f(xy + 1) = f(x) \cdot f(y) - f(y) - x + 2$

កំនត់អនុគមន៍ $f(x)$

សម្រាយបញ្ជាក់

១. កំនត់ចំនួនគត់ធម្មជាតិ n

ឧបមាថា $A=n^4+6n^3+11n^2+3n+31$ ជាការេប្រាកដ

$\Rightarrow A=\left(n^2+3n+1\right)^2-3(n-10)$ ជាការេប្រាកដ

• បើ $n>10\Rightarrow A<\left(n^2+3n+1\right)^2\Rightarrow A\le\left(n^2+3n\right)^2$

$\Rightarrow\left(n^2+3n+1\right)^2-3(n-10)\le\left(n^2+3n\right)^2$

$\Rightarrow\left(n^2+3n+1\right)^2-\left(n^2+3n\right)^2\le 3n-30$

$\Rightarrow\left(n^2+3n+1+n^2+3n\right)\left(n^2+3n+1-n^2-3n\right)\le 3n-30$

$\Rightarrow 2n^2+6n+1\le 3n-30$

$\Rightarrow 2n^2+3n+31\le 0$ មិនពិតព្រោះ n ជាចំនួនគត់ធម្មជាតិ

• បើ $n=10\Rightarrow A=\left(10^2+3\cdot 10+1\right)^2=131^2$ ជាការេប្រាកដ

• បើ $n<10\Rightarrow A>\left(n^2+3n+1\right)^2$ និង $n^2+3n\ge 0$

$\Rightarrow A\ge\left(n^2+3n+2\right)^2$

$\Rightarrow\left(n^2+3n+1\right)^2-3(n-10)\ge\left(n^2+3n+2\right)^2$

$\Rightarrow 2n^2+9n-27\le 0$

$$\Rightarrow\frac{-3\left(\sqrt{33}+3\right)}{4}\le n\le\frac{3\left(\sqrt{33}-3\right)}{4}<3$$

$\Rightarrow n=\{0,1,2\}$ ហើយចំពោះ n ទាំងអស់នេះ យើងបានតំលៃ

$A=\{31,52,145\}$ ដែលមិនមែនជាការប្រាកដទេ

ដូចនេះ $n=10$

២. បង្ហាញថា $x^2+4y^2<1$

តាមសម្មតិកម្ម $x,y\in\mathbb{R}_+$ យើងបាន $x^3+y^3>0$

ដោយ $x^3+y^3=x-y$ នោះដើម្បីបង្ហាញថា $x^2+4y^2<1$

យើងគ្រាន់តែបង្ហាញថា $x^3+y^3>(x-y)(x^2+4y^2)$

$\Leftrightarrow x^3+y^3>x^3+4xy^2-x^2y-4y^3$

$\Leftrightarrow 5y^3+x^2y>4xy^2$ ពិត ព្រោះតាមវិសមភាព កូស៊ី យើងបាន

$5y^3+x^2y\geq 2\sqrt{5y^3x^2y}=2\sqrt{5}xy^2>4xy^2$

ដូចនេះ $x^2+4y^2<1$

៣. កំនត់តំលៃអប្បបរមានៃចំនួនថេរ λ

របៀបទី១. តាមវិសមភាព កូស៊ី ចំពោះ $u,v,w\in\mathbb{R}_+$

យើងបាន $\frac{u+v}{2}\geq\sqrt{uv};\quad \frac{v+w}{2}\geq\sqrt{vw};\quad \frac{u+w}{2}\geq\sqrt{uw}$

$\Rightarrow u\cdot\frac{v+w}{2}+v\cdot\frac{u+w}{2}+w\cdot\frac{u+v}{2}\geq u\sqrt{vw}+v\sqrt{wu}+w\sqrt{uv}\geq 1$

$\Rightarrow \frac{uv}{2}+\frac{uw}{2}+\frac{uv}{2}+\frac{vw}{2}+\frac{uw}{2}+\frac{vw}{2}\geq 1$

$\Rightarrow uv+vw+uw\geq 1$

ម្យ៉ាងទៀត $(u-v)^2+(v-w)^2+(u-w)^2\geq 0$

$\Rightarrow 2(u^2+v^2+w^2)-2(uv+vw+uw)\geq 0$

$\Rightarrow u^2+v^2+w^2\geq uv+vw+uw\geq 1$

ដោយ $(u+v+w)^2=\left(u^2+v^2+w^2\right)+2(uv+vw+uw)$

$\Rightarrow (u+v+w)^2 \geq 1+2\times 1=3$

$\Rightarrow u+v+w \geq \sqrt{3}$

<u>ដូចនេះ</u> $\lambda=\sqrt{3}$

<u>របៀបទី២.</u>

យើងមាន $\dfrac{(u+v+w)^4}{9}=\left(\dfrac{u+v+w}{3}\right)^3\cdot 3(u+v+w)$

តាមវិសមភាព កូស៊ី យើងបាន

$\dfrac{u+v+w}{3} \geq \sqrt[3]{uvw} \quad \Rightarrow \left(\dfrac{u+v+w}{3}\right)^3 \geq uvw$

$\Rightarrow \dfrac{(u+v+w)^4}{9} \geq 3uvw(u+v+w)$

$\Rightarrow \dfrac{(u+v+w)^4}{9} \geq (uvw+uvw+uvw)(u+v+w)$

តាមវិសមភាព កូស៊ី ស្វាត យើងបាន

$$(uvw+uvw+uvw)(u+v+w) \geq \left(\sqrt{uvwu}+\sqrt{uvwv}+\sqrt{uvww}\right)^2$$

$$\geq \left(u\sqrt{vw}+v\sqrt{uw}+w\sqrt{uv}\right)^2$$

$$\geq 1$$

នាំអោយ $\dfrac{(u+v+w)^4}{9} \geq 1 \quad \Rightarrow (u+v+w)^4 \geq 9$

$\Rightarrow u+v+w\geq\sqrt{3}$

ដូចនេះ $\lambda=\sqrt{3}$

របៀបទី៣.

តាង $x=\sqrt{uv};\quad y=\sqrt{vw};\quad z=\sqrt{uw}$

យើងបាន $xy+yz+zx=\sqrt{uvvw}+\sqrt{vwwu}+\sqrt{wuuv}$

$$=v\sqrt{uw}+w\sqrt{uv}+u\sqrt{vw}$$

$$=u\sqrt{vw}+v\sqrt{uw}+w\sqrt{uv}\geq 1$$

នាំអោយ $xy+yz+zx\geq 1$

និង $u=\frac{xz}{y};\quad v=\frac{xy}{z};\quad w=\frac{yz}{x}$

$$\Rightarrow 2(u+v+w)=\left(\frac{xz}{y}+\frac{xy}{z}\right)+\left(\frac{xy}{z}+\frac{yz}{x}\right)+\left(\frac{yz}{x}+\frac{xz}{y}\right)$$

$$\geq 2\sqrt{\frac{xz}{y}\cdot\frac{xy}{z}}+2\sqrt{\frac{xy}{z}\cdot\frac{yz}{x}}+2\sqrt{\frac{yz}{x}\cdot\frac{xz}{y}}$$

$\Rightarrow 2(u+v+w)\geq 2(x+y+z)$

$\Rightarrow u+v+w\geq x+y+z \qquad (*)$

ម្យ៉ាងទៀត $(x-y)^2+(y-z)^2+(z-x)^2\geq 0$

$\Rightarrow 2\left(x^2+y^2+z^2\right)-2(xy+yz+zx)\geq 0$

$\Rightarrow x^2+y^2+z^2\geq xy+yz+zx\geq 1$

ដោយ $(x+y+z)^2=\left(x^2+y^2+z^2\right)+2(xy+yz+zx)$

$\Rightarrow (x+y+z)^2\geq 1+2\cdot 1=3$

$\Rightarrow x+y+z\geq\sqrt{3}$

តាម $(*)$ យើងបាន $u+v+w\geq\sqrt{3}$

ដូចនេះ $\lambda=\sqrt{3}$

៩. គណនាអាំងតេក្រាល៖

ក. $I=\int\frac{4x^2+8x+7}{x^2+6x+10}dx=\int\frac{4x^2+24x+40-16x-33}{x^2+6x+10}dx$

$=\int\frac{4\left(x^2+6x+10\right)-16x-33}{x^2+6x+10}dx=\int 4dx-\int\frac{16x+33}{x^2+6x+10}dx$

$=4x-\int\frac{16x+33}{x^2+6x+10}dx$

ដោយ $\int\frac{16x+33}{x^2+6x+10}dx=\int\frac{8(2x+6)-15}{x^2+6x+10}dx$

$=8\int\frac{\left(x^2+6x+10\right)'}{x^2+6x+10}dx-15\int\frac{1}{x^2+6x+10}dx$

$=8\ln\left|x^2+6x+10\right|-15\int\frac{1}{(x+3)^2+1}dx$

$=8\ln\left|x^2+6x+10\right|-15\arctan(x+3)+C$ ដែល $C\in\mathbb{R}$

ដូច្នេះ $I=4x-8\ln\left|x^2+6x+10\right|+15\arctan(x+3)+C$

ខ. $J=\int\frac{2x^3-5x^2+6x+2}{x^2-x-1}dx$

$$=\int\frac{2x^3-2x^2-2x-3x^2+3x+3+5x-1}{x^2-x-1}dx$$
$$=\int\frac{2x\left(x^2-x-1\right)-3\left(x^2-x-1\right)+5x-1}{x^2-x-1}dx$$
$$=\int 2xdx+\int(-3)dx+\int\frac{5x-1}{x^2-x-1}dx=x^2-3x+\int\frac{5x-1}{x^2-x-1}dx$$

ដោយ $\int\frac{5x-1}{x^2-x-1}dx=\int\frac{\frac{5}{2}(2x-1)+\frac{5}{2}-1}{x^2-x-1}dx$

$$=\frac{5}{2}\int\frac{\left(x^2-x-1\right)'}{x^2-x-1}dx+\frac{3}{2}\int\frac{1}{x^2-x-1}dx$$
$$=\frac{5}{2}\ln\left|x^2-x-1\right|+\frac{3}{2}\int\frac{dx}{\left(x-\frac{1}{2}\right)^2-\frac{5}{4}}$$
$$=\frac{5}{2}\ln\left|x^2-x-1\right|+\frac{3}{2}\cdot\frac{1}{2\sqrt{\frac{5}{4}}}\ln\left|\frac{x-\frac{1}{2}-\frac{\sqrt{5}}{2}}{x-\frac{1}{2}+\frac{\sqrt{5}}{2}}\right|+C$$ ដែល $C\in\mathbb{R}$

<u>ដូច្នេះ</u>

$$J=x^2-3x+\frac{5}{2}\ln\left|x^2-x-1\right|+\frac{3}{2\sqrt{5}}\ln\left|\frac{2x-1-\sqrt{5}}{2x-1+\sqrt{5}}\right|+C$$

៥. កំនត់តំលៃអប្បបរមានៃ A

តាង $x=a+2b+c;\ \ y=a+b+2c$ និង $z=a+b+3c$

យើងបាន $z-y=c$ និង $x-y=b-c$

$\Rightarrow x-y=b-(z-y)$

$\Rightarrow b=x+z-2y$ និង $a+3c=2y-x$

នាំអោយ $A=\dfrac{a+3c}{a+2b+c}+\dfrac{4b}{a+b+2c}-\dfrac{8c}{a+b+3c}$

$$=\frac{2y-x}{x}+\frac{4(x+z-2y)}{y}-\frac{8(z-y)}{z}$$

$$=2\cdot\frac{y}{x}-1+4\cdot\frac{x}{y}+4\cdot\frac{z}{y}-8-8+8\cdot\frac{y}{z}$$

$$=-17+2\cdot\frac{y}{x}+4\cdot\frac{x}{y}+4\cdot\frac{z}{y}+8\cdot\frac{y}{z}$$

តាមវិសមភាព កូស៊ី

$$2\cdot\frac{y}{x}+4\cdot\frac{x}{y}\geq 2\cdot\sqrt{2\cdot\frac{y}{x}\cdot 4\cdot\frac{x}{y}}=2\sqrt{8}=4\sqrt{2}$$

$$4\cdot\frac{z}{y}+8\cdot\frac{y}{z}\geq 2\cdot\sqrt{4\cdot\frac{z}{y}\cdot 8\cdot\frac{y}{z}}=2\sqrt{32}=8\sqrt{2}$$

នាំអោយ $A\geq -17+4\sqrt{2}+8\sqrt{2}=-17+12\sqrt{2}$

សញ្ញាស្មើកើតមាននៅពេលដែល $\dfrac{2y}{x}=\dfrac{4x}{y}$ និង $\dfrac{4z}{y}=\dfrac{8y}{z}$

ឬ $4x^2=2y^2=z^2$

យើងបាន ប្រព័ន្ធសមីការ

$$\begin{cases} a+b+2c=\sqrt{2}(a+2b+c) \\ a+b+3c=2(a+2b+c) \end{cases}$$

ដោយដោះស្រាយសមីការអញ្ញត្តិ b និង c ហើយយក a ជាប៉ារ៉ាម៉ែត្រ

នាំអោយ $b=\left(1+\sqrt{2}\right)a$ និង $c=\left(4+3\sqrt{2}\right)a$

ដូច្នេះ តំលៃអប្បបរមានៃ A គឺ $\min(A)=-17+12\sqrt{2}$

៦. កំនត់អនុគមន៍ $f(x)$

យើងមាន $f(xy+1)=f(x)\cdot f(y)-f(y)-x+2$ ចំពោះគ្រប់តំលៃ $x,y\in\mathbb{R}$

យើងបាន $f(yx+1)=f(y)\cdot f(x)-f(x)-y+2$

ដោយ $f(xy+1)=f(yx+1)$

$\Rightarrow f(x)\cdot f(y)-f(y)-x+2=f(y)\cdot f(x)-f(x)-y+2$

$\Rightarrow f(x)+y=f(y)+x$

ជំនួស $x=0 \Rightarrow f(0)+y=f(y)+0$ ដោយ $f(0)=1$

យើងបាន $f(y)=1+y$

ដូច្នេះ $f(x)=x+1$ ចំពោះគ្រប់តំលៃ $x\in\mathbb{R}$

វិញ្ញាសាទី៨

១. ចំពោះតំលៃ $n \in \mathbb{N}^*$ បង្ហាញថា $1+x^2+x^4+\cdots+x^{2n-2}$ ចែកដាច់នឹង $1+x+x^2+\cdots+x^{n-1}$ ។

២. គណនា $x \in \mathbb{N}^*$ ដើម្បីអោយ $\overline{xxx(x-1)} = (x-1)^{x-2}$ ។

៣. គេអោយ x_1, x_2, x_3, x_4, x_5 ជាចំនួនពិតមិនអវិជ្ជមាន ហើយផ្ទៀងផ្ទាត់ $\frac{1}{1+x_1}+\frac{1}{1+x_2}+\frac{1}{1+x_3}+\frac{1}{1+x_4}+\frac{1}{1+x_5}=1$ ។

បង្ហាញថា $\frac{x_1}{4+x_1^2}+\frac{x_2}{4+x_2^2}+\frac{x_3}{4+x_3^2}+\frac{x_4}{4+x_4^2}+\frac{x_5}{4+x_5^2}\le 1$

៤. បង្ហាញថា $\tan x + 2\tan 2x + 4\tan 4x + 8\cot 8x = \cot x$ ចំពោះគ្រប់តំលៃ $x \in \mathbb{R}$ ។

៥. កំនត់គ្រប់អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ៖ $f(x+y)+f(y+z)+f(z+x)\ge 3f(x+2y+3z)$ ចំពោះគ្រប់តំលៃ x, y, z ។

៦. ឧបមាថា $a+b$ និង $a-b$ ជាចំនួនបឋមរវាងគ្នា។ រកតួចែករួមធំបំផុតនៃ $2a+(1+2a)(a^2-b^2)$ និង $2a(a^2+2a-b^2)(a^2-b^2)$ ។

សម្រាយបញ្ជាក់

១. យើងមាន $\left(x^2-1\right)\left(1+x^2+x^4+\cdots+x^{2n-2}\right)=x^{2n}-1$

$\Rightarrow(x-1)(x+1)\left(1+x^2+x^4+\cdots+x^{2n-2}\right)=\left(x^n-1\right)\left(x^n+1\right)$

ដោយ $x^n-1=(x-1)\left(x^{n-1}+x^{n-2}+\cdots+x+1\right)$

$x^n+1=(x+1)\left(x^{n-1}-x^{n-2}+\cdots+(-1)^{n-2}x+(-1)^{n-1}\right)$

នាំអោយ $1+x^2+x^4+\cdots+x^{2n-2}=K\left(1+x+x^2+\cdots+x^{n-1}\right)$

ដែល $K=x^{n-1}-x^{n-2}+\cdots+(-1)^{n-2}x+(-1)^{n-1}\in\mathbb{Z}$

ដូច្នេះ $1+x^2+x^4+\cdots+x^{2n-2}$ ចែកដាច់នឹង $1+x+x^2+\cdots+x^{n-1}$

២. គណនា $x\in\mathbb{N}^*$

យើងមាន $\overline{xxx(x-1)}=(x-1)^{x-2}$

ដោយ $1000\le\overline{xxx(x-1)}<10000$ ហើយ $x\in\mathbb{N}^*$

នាំអោយ $1\le x\le 9$

$\Rightarrow 1000\le(x-1)^{x-2}<10000$

ដោយ $5^4=625<1000$ និង $7^6=343243>10000$

យើងបាន $5^4<(x-1)^{x-2}<7^6$

$\Rightarrow(x-1)^{x-2}=6^5 \qquad \Rightarrow x=7$

ដូច្នេះ $x=7$

៣.បង្ហាញថា $\sum_{i=1}^{5}\frac{x_i}{4+x_i^2}\le 1$

តាង $y_i=\frac{1}{1+x_i}$ ចំពោះ $i=\overline{1,5}$

$\Rightarrow x_i=\frac{1-y_i}{y_i}$ ហើយ $\sum_{i=1}^{5}y_i=1$

ឧបមាថា$\sum_{i=1}^{5}\frac{x_i}{4+x_i^2}\le 1 \Leftrightarrow \sum_{i=1}^{5}\frac{\frac{1-y_i}{y_i}}{4+\left(\frac{1-y_i}{y_i}\right)^2}\le 1$

$$\Leftrightarrow \sum_{i=1}^{5}\frac{y_i-y_i^2}{4y_i^2+1-2y_i+y_i^2}\le 1$$

$$\Leftrightarrow \sum_{i=1}^{5}\frac{y_i-y_i^2}{5y_i^2-2y_i+1}\le 1$$

$$\Leftrightarrow \sum_{i=1}^{5}\frac{5y_i-5y_i^2}{5y_i^2-2y_i+1}\le 5$$

$$\Leftrightarrow \sum_{i=1}^{5}\frac{-\left(5y_i^2-2y_i+1\right)+3y_i+1}{5y_i^2-2y_i+1}\le 5$$

$$\Leftrightarrow \sum_{i=1}^{5}\left(-1+\frac{3y_i+1}{5y_i^2-2y_i+1}\right)\le 5$$

$$\Leftrightarrow \sum_{i=1}^{5}\frac{3y_i+1}{5y_i^2-2y_i+1}\le 10$$

$$\Leftrightarrow \sum_{i=1}^{5} \frac{3y_i+1}{5\left(y_i^2 - 2\cdot\frac{1}{5}y_i + \frac{1}{25}\right) + \frac{4}{5}} \le 10 \qquad (*)$$

$$\Leftrightarrow \sum_{i=1}^{5} \frac{3y_i+1}{5\left(y_i - \frac{1}{5}\right)^2 + \frac{4}{5}} \le 10$$

ម្យ៉ាងទៀត $\sum_{i=1}^{5} \frac{3y_i+1}{5\left(y_i - \frac{1}{5}\right)^2 + \frac{4}{5}} \le \sum_{i=1}^{5} \frac{3y_i+1}{\frac{4}{5}} = \frac{5}{4}\sum_{i=1}^{5}(3y_i+1)$

$$\Rightarrow \sum_{i=1}^{5} \frac{3y_i+1}{5\left(y_i - \frac{1}{5}\right)^2 + \frac{4}{5}} \le \frac{5}{4}\left(3\sum_{i=1}^{5} y_i + \sum_{i=1}^{5} 1\right) = \frac{5}{4}(3\times 1 + 5) = 10$$

យើងបាន $(*)$ ពិត នាំអោយ ការឧបមាខាងលើពិត

ដូច្នេះ $\sum_{i=1}^{5} \frac{x_i}{4+x_i^2} \le 1$

៩. បង្ហាញថា $\tan x + 2\tan 2x + 4\tan 4x + 8\cot 8x = \cot x$

តាង $f(x) = \tan x - \cot x + 2\tan 2x + 4\tan 4x + 8\cot 8x$

$$\Rightarrow f'(x) = \frac{1}{\cos^2 x} + \frac{1}{\sin^2 x} + \frac{4}{\cos^2 2x} + \frac{16}{\cos^2 4x} - \frac{64}{\sin^2 8x}$$

$$= \frac{\sin^2 x + \cos^2 x}{\sin^2 x\cos^2 x} + \frac{4}{\cos^2 2x} + \frac{16}{\cos^2 4x} - \frac{64}{\sin^2 8x}$$

$$= \frac{4}{\sin^2 2x} + \frac{4}{\cos^2 2x} + \frac{16}{\cos^2 4x} - \frac{64}{\sin^2 8x}$$

$$= \frac{16}{\sin^2 4x} + \frac{16}{\cos^2 4x} - \frac{64}{\sin^2 8x}$$
$$= \frac{64}{\sin^2 8x} - \frac{64}{\sin^2 8x} = 0$$

នាំអោយ f ជាអនុគមន៍ថេរ ចំពោះគ្រប់តំលៃ x

ដោយ $f\left(\frac{\pi}{6}\right) = \tan\frac{\pi}{6} - \cot\frac{\pi}{6} + 2\tan\frac{\pi}{3} + 4\tan\frac{2\pi}{3} + 8\cot\frac{4\pi}{3}$

$$= \frac{\sqrt{3}}{3} - \sqrt{3} + 2\sqrt{3} + 4\left(-\sqrt{3}\right) + 8\left(\frac{\sqrt{3}}{3}\right) = 0$$

នាំអោយ $f(x) = 0$ ចំពោះ គ្រប់តំលៃ $x \in \mathbb{R}$

$\Rightarrow \tan x - \cot x + 2\tan 2x + 4\tan 4x + 8\cot 8x = 0$

$\Rightarrow \tan x + 2\tan 2x + 4\tan 4x + 8\cot 8x = \cot x$

<u>ដូចេ្នះ</u> $\tan x + 2\tan 2x + 4\tan 4x + 8\cot 8x = \cot x$

៥. កំនត់អនុគមន៍ f

យក $x = a$ និង $y = z = 0$

យើងបាន $f(a) + f(0) + f(a) \geq 3f(a)$

$\Rightarrow f(a) \leq f(0)$ $\quad (*)$

យក $x = \frac{a}{2}$; $y = \frac{a}{2}$ និង $z = -\frac{a}{2}$

យើងបាន $f(a) + f(0) + f(0) \geq 3f(0)$

$\Rightarrow f(a) \geq f(0)$ $\quad (**)$

តាម $(*)$ និង $(**)$

នាំអោយ $f(a) = f(0)$ $\Rightarrow f$ ជាអនុគមន៍ថេរ

ដោយ គ្រប់អនុគមន៍ថេរ សុទ្ធតែផ្ទៀងផ្ទាត់លក្ខខណ្ឌខាងលើ

យើងបាន $f(x)=c$ ចំពោះគ្រប់តំលៃ $c\in\mathbb{R}$

ដូច្នេះ $f(x)=c$ ចំពោះគ្រប់តំលៃ $c\in\mathbb{R}$

៦. តាង (r,s) ជាតួចែករួមធំបំផុតនៃ r និង s

ប្រសិនបើ $(r,s)=1$ នាំអោយមាន ចំនួនបឋម p ចែកដាច់ rs

នាំអោយ p ចែកដាច់ r ឬ p ចែកដាច់ s តែ p មិនអាចចែកដាច់ r និង s ព្រមគ្នាបានទេ

$\Rightarrow p$ ចែកមិនដាច់ $r+s$

$\Rightarrow (rs,r+s)=1$

តាង $x=a+b,\quad y=a-b$

យើងបាន $2a+(1+2a)(a^2-b^2)=x+y+(1+x+y)xy$

$$=(x+y+xy)+(x+y)xy$$

និង $2a(a^2+2a-b^2)(a^2-b^2)=(x+y)(xy+x+y)xy$

បើ $(x,y)=1\quad\Rightarrow(x+y,xy)=1$

$(x+y,xy)=1\ \Rightarrow(x+y+xy,(x+y)xy)=1$

ហើយ $(x+y+xy,(x+y)xy)=1$

នាំអោយ

$(x+y+xy+(x+y)xy,(x+y+xy)(x+y)xy)=1$

ដូច្នេះ តួរចែករួមធំបំផុតនៃ $2a+(1+2a)(a^2-b^2)$ និង $2a(a^2+2a-b^2)(a^2-b^2)$ គឺ 1

វិញ្ញាសាទី៤

១. បង្ហាញថា $\left(\sqrt{3}+\sqrt{2}\right)^{\frac{1}{n}}+\left(\sqrt{3}-\sqrt{2}\right)^{\frac{1}{n}}$ ជាចំនួនអសនិទាន ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ។

២. ដោះស្រាយប្រព័ន្ធសមីការ៖

$$\begin{cases} \log_2 x+\log_4 y+\log_4 z=2 & (1) \\ \log_3 y+\log_9 z+\log_9 x=2 & (2) \\ \log_4 z+\log_{16} x+\log_{16} y=2 & (3) \end{cases}$$

៣. គេអោយ $a=\tan\alpha$ ។ បង្ហាញថា $\tan 5\alpha=\dfrac{5a-10a^3+a^5}{1-10a^2+5a^4}$

៤. គេអោយ $A=\begin{pmatrix} 1 & 0 \\ -1 & 2 \end{pmatrix}$ ។ បង្ហាញថា $A^n=\begin{pmatrix} 1 & 0 \\ 1-2^n & 2^n \end{pmatrix}$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ។

៥. គណនាតំលៃអតិបរមានិងអប្បបរមានៃ

$$y=\frac{2+\cos x}{\sin x+\cos x-2}$$

៦. គេអោយ $f_1(x)=\dfrac{x}{\sqrt[3]{1+x^3}}$ និង $f_n(x)=f\left[f_{n-1}(x)\right]$ ។

គណនា $f_n(x)$

សម្រាយបញ្ជាក់

១. តាង $x=\left(\sqrt{3}+\sqrt{2}\right)^{\frac{1}{n}} \quad \Rightarrow x^{-1}=\left(\sqrt{3}-\sqrt{2}\right)^{\frac{1}{n}}$

ឧបមាថា $x+x^{-1}$ ជាចំនួនសនិទាន

យើងបាន $x^2+x^{-2}=\left(x+x^{-1}\right)^2-2$ ជាចំនួនសនិទាន

ឧបមាថា ពិតដល់ n គឺ x^n+x^{-n} ជាចំនួនសនិទាន

យើងនឹងបង្ហាញថា ពិតដល់ $n+1$

ដោយ $x^{n+1}+x^{-(n+1)}=\left(x+x^{-1}\right)\left(x^n+x^{-n}\right)-\left(x^{n-1}+x^{-(n-1)}\right)$

យើងបាន $x^{n+1}+x^{-(n+1)}$ ជាចំនួនសនិទាន

នាំអោយ x^n+x^{-n} ជាចំនួនសនិទាន

ប៉ុន្តែ $x^n+x^{-n}=\sqrt{3}+\sqrt{2}+\sqrt{3}-\sqrt{2}=2\sqrt{3}$ ជាចំនួន
អសនិទាន (សំនើរ ផ្ទុយ)

នាំអោយ $x+x^{-1}$ ជាចំនួនអសនិទាន

ដូច្នេះ $\left(\sqrt{3}+\sqrt{2}\right)^{\frac{1}{n}}+\left(\sqrt{3}-\sqrt{2}\right)^{\frac{1}{n}}$ ជាចំនួនអសនិទាន

២. ដោះស្រាយប្រព័ន្ធសមីការ៖

លក្ខខណ្ឌ $x,y,z>0$

តាម (1) $\Rightarrow \log_2 x+\frac{1}{2}\log_2 y+\frac{1}{2}\log_2 z=2$

$$\Rightarrow \log_2 x+\log_2\sqrt{y}+\log_2\sqrt{z}=2$$

$$\Rightarrow \log_2\left(x\sqrt{yz}\right)=2 \quad \Rightarrow x\sqrt{yz}=2^2$$

$$\Rightarrow x^2yz=2^4 \qquad (4)$$

តាម (2) $\Rightarrow \log_3 y+\frac{1}{2}\log_3 z+\frac{1}{2}\log_3 x=2$

$$\Rightarrow \log_3 y+\log_3\sqrt{z}+\log_3\sqrt{x}=2$$

$$\Rightarrow \log_3 y\sqrt{xz}=2 \quad \Rightarrow y\sqrt{zx}=3^2$$

$$\Rightarrow y^2zx=3^4 \qquad (5)$$

តាម (3) $\Rightarrow \log_4 z+\frac{1}{2}\log_4 x+\frac{1}{2}\log_4 y=2$

$$\Rightarrow \log_4 z+\log_4\sqrt{x}+\log_4\sqrt{y}=2$$

$$\Rightarrow \log_4 z\sqrt{xy}=2 \quad \Rightarrow z\sqrt{xy}=4^2$$

$$\Rightarrow z^2xy=4^4 \qquad (6)$$

យក (4) គុណ (5) គុណ (6)

យើងបាន $(xyz)^4=24^4 \quad \Rightarrow xyz=24$

តាម (4) $\Rightarrow x=\frac{2^4}{xyz}=\frac{2^4}{24}=\frac{2}{3}$

តាម (5) $\Rightarrow y=\frac{3^4}{xyz}=\frac{3^4}{24}=\frac{27}{8}$

តាម (6) $\Rightarrow z=\frac{4^4}{xyz}=\frac{4^4}{24}=\frac{32}{3}$

ដូច្នេះ $\{x,y,z\}=\left\{\frac{2}{3},\frac{27}{8},\frac{32}{3}\right\}$

៣. តាមទ្រឹស្តីបទ ដឺម័រ

យើងបាន $(\cos\alpha + i\sin\alpha)^5 = \cos 5\alpha + i\sin 5\alpha \qquad (*)$

ម្យ៉ាងទៀត $(\cos\alpha + i\sin\alpha)^5 = \cos^5\alpha + 5\cos^4\alpha(i\sin\alpha) +$

$10\cos^3\alpha(i\sin\alpha)^2 + 10\cos^2\alpha(i\sin\alpha)^3 + 5\cos\alpha(i\sin\alpha)^4 + (i\sin\alpha)^5$

$= \cos^5\alpha + 5i\cos^4\alpha\sin\alpha - 10\cos^3\alpha\sin^2\alpha - 10i\cos^2\alpha\sin^3\alpha +$

$5\cos\alpha\sin^4\alpha + i\sin^5\alpha$

$= \left(\cos^5\alpha - 10\cos^3\alpha\sin^2\alpha + 5\cos\alpha\sin^4\alpha\right)$

$+ i\left(5\cos^4\alpha\sin\alpha - 10\cos^2\alpha\sin^3\alpha + \sin^5\alpha\right) \qquad (**)$

តាម $(*)$ និង $(**)$ យើងបាន

$$\begin{cases} \cos 5\alpha = \cos^5\alpha - 10\cos^3\alpha\sin^2\alpha + 5\cos\alpha\sin^4\alpha \\ \sin 5\alpha = 5\cos^4\alpha\sin\alpha - 10\cos^2\alpha\sin^3\alpha + \sin^5\alpha \end{cases}$$

$$\Rightarrow \tan 5\alpha = \frac{\sin 5\alpha}{\cos 5\alpha} = \frac{5\cos^4\alpha\sin\alpha - 10\cos^2\alpha\sin^3\alpha + \sin^5\alpha}{\cos^5\alpha - 10\cos^3\alpha\sin^2\alpha + 5\cos\alpha\sin^4\alpha}$$

$$\Rightarrow \tan 5\alpha = \frac{\dfrac{5\cos^4\alpha\sin\alpha - 10\cos^2\alpha\sin^3\alpha + \sin^5\alpha}{\cos^5\alpha}}{\dfrac{\cos^5\alpha - 10\cos^3\alpha\sin^2\alpha + 5\cos\alpha\sin^4\alpha}{\cos^5\alpha}}$$

$$\Rightarrow \tan 5\alpha = \frac{5\tan\alpha - 10\tan^3\alpha + \tan^5\alpha}{1 - 10\tan^2\alpha + 5\tan^4\alpha}$$ យក $a = \tan\alpha$

យើងបាន $\tan 5\alpha = \dfrac{5a - 10a^3 + a^5}{1 - 10a^2 + 5a^4}$

<u>ដូច្នេះ</u> $\tan 5\alpha = \dfrac{5a - 10a^3 + a^5}{1 - 10a^2 + 5a^4}$ ដែល $a = \tan\alpha$

៤. យើងមាន $A=\begin{pmatrix}1 & 0\\ -1 & 2\end{pmatrix}=\begin{pmatrix}1 & 0\\ 1-2^1 & 2^1\end{pmatrix}$

$$A^2=A\cdot A=\begin{pmatrix}1 & 0\\ -1 & 2\end{pmatrix}\begin{pmatrix}1 & 0\\ -1 & 2\end{pmatrix}=\begin{pmatrix}1\cdot 1+0(-1) & 1\cdot 0+0\cdot 2\\ (-1)\cdot 1+2(-1) & (-1)\cdot 0+2\cdot 2\end{pmatrix}$$

$$=\begin{pmatrix}1 & 0\\ -3 & 4\end{pmatrix}=\begin{pmatrix}1 & 0\\ 1-2^2 & 2^2\end{pmatrix}$$

ឧបមាថា ពិតដល់ n គឺ $A^n=\begin{pmatrix}1 & 0\\ 1-2^n & 2^n\end{pmatrix}$

យើងនឹង បង្ហាញថាពិតដល់ $n+1$

យើងបាន $A^{n+1}=A\cdot A^n=\begin{pmatrix}1 & 0\\ -1 & 2\end{pmatrix}\begin{pmatrix}1 & 0\\ 1-2^n & 2^n\end{pmatrix}$

$$=\begin{pmatrix}1\cdot 1+0(1-2^n) & 1\cdot 0+0\cdot 2^n\\ (-1)\cdot 1+2(1-2^n) & (-1)\cdot 0+2\cdot 2^n\end{pmatrix}=\begin{pmatrix}1 & 0\\ 1-2^{n+1} & 2^{n+1}\end{pmatrix}$$

ពិត

<u>ដូច្នេះ</u> $A^n=\begin{pmatrix}1 & 0\\ 1-2^n & 2^n\end{pmatrix}$

៥. យើងមាន $y=\dfrac{2+\cos x}{\sin x+\cos x-2}$

$\Leftrightarrow y(\sin x+\cos x-2)=2+\cos x$

$\Leftrightarrow y\sin x+(y-1)\cos x=2(y+1)$

$\Leftrightarrow \left[y\sin x+(y-1)\cos x\right]^2=\left[2(y+1)\right]^2 \qquad (*)$

តាមវិសមភាព កូស៊ី ស្វាត

$$\left[y\sin x+(y-1)\cos x\right]^2\le\left[y^2+(y-1)^2\right](\sin^2 x+\cos^2 x)$$

$$\le y^2+y^2-2y+1$$

តាម $(*)$ $\Rightarrow\left[2(y+1)\right]^2\le 2y^2-2y+1$

$$\Rightarrow 4y^2+8y+4\le 2y^2-2y+1$$

$$\Rightarrow 2y^2+10y+3\le 0$$

$$\Rightarrow \frac{-5-\sqrt{19}}{2}\le y\le\frac{-5+\sqrt{19}}{2}$$

<u>ដូច្នេះ</u> $\min(y)=\dfrac{-5-\sqrt{19}}{2}$ និង $\max(y)=\dfrac{-5+\sqrt{19}}{2}$

៦. គណនា $f_n(x)$

យើងមាន $f_1(x)=\dfrac{x}{\sqrt[3]{1+x^3}}$

$$\Rightarrow f_2(x)=f\left[f_1(x)\right]=\frac{f_1(x)}{\sqrt[3]{1+f_1^{\,3}(x)}}=\frac{\dfrac{x}{\sqrt[3]{1+x^3}}}{\sqrt[3]{1+\left(\dfrac{x}{\sqrt[3]{1+x^3}}\right)^3}}$$

$$=\frac{\dfrac{x}{\sqrt[3]{1+x^3}}}{\sqrt[3]{1+\dfrac{x^3}{1+x^3}}}=\frac{x}{\sqrt[3]{1+x^3}\cdot\dfrac{\sqrt[3]{1+2x^3}}{\sqrt[3]{1+x^3}}}=\frac{x}{\sqrt[3]{1+2x^3}}$$

ឧបមាថា វាពិតដល់ n គឺ៖ $f_n(x)=\dfrac{x}{\sqrt[3]{1+nx^3}}$

យើងនឹងបង្ហាញថាពិតដល់ $n+1$

$$f_{n+1}(x)=f\left[f_n(x)\right]=\frac{f_n(x)}{\sqrt[3]{1+f_n^{\,3}(x)}}=\frac{\dfrac{x}{\sqrt[3]{1+nx^3}}}{\sqrt[3]{1+\left(\dfrac{x}{\sqrt[3]{1+nx^3}}\right)^3}}$$

$$=\frac{\dfrac{x}{\sqrt[3]{1+nx^3}}}{\sqrt[3]{1+\dfrac{x^3}{1+nx^3}}}=\frac{x}{\sqrt[3]{1+nx^3}\cdot\dfrac{\sqrt[3]{1+(n+1)x^3}}{\sqrt[3]{1+nx^3}}}=\frac{x}{\sqrt[3]{1+(n+1)x^3}}$$

ពិត

ដូច្នេះ $\quad f_n(x)=\dfrac{x}{\sqrt[3]{1+nx^3}}$

វិញ្ញាសាទី៦

១. គេអោយត្រីកោណ ABC ។

បង្ហាញថា $\cot A\cot B+\cot B\cot C+\cot A\cot C=1$ ។

រួចទាញបញ្ជាក់ថា $\tan A+\tan B+\tan C=\tan A\tan B\tan C$

២. គណនាបណ្តាចំនួនគត់ធម្មជាតិ x,y,z ដែលផ្ទៀងផ្ទាត់ $x^z y=x+y^z$ ។

៣. ចំពោះគ្រប់ x,y,z ជាចំនួនពិត ដែល $x^2+y^2+z^2=9$ ។

បង្ហាញថា $2(x+y+z)-xyz\leq 10$ ។ តើសញ្ញាស្មើកើតមាននៅពេលណា?

៤. គេអោយ u,v,w ជាចំនួនកុំផ្លិច ដែលមាន ម៉ូឌុលស្មើ 1 ។

បង្ហាញថា $|uv+vw+uw|=|u+v+w|$

៥. គណនាតួទូទៅនៃស្វ៊ីត $(a_n)_{n\in\mathbb{N}}$ និង $(b_n)_{n\in\mathbb{N}}$ ដែលផ្ទៀងផ្ទាត់៖

ក. $\{a_n\}=\{1,3,10,22,39,...\}$

ខ. $\{b_n\}=\{1,4,13,40,121,...\}$

៦. គេអោយ $I_n=\int_0^1 x^n\cos\pi x dx$ ចំពោះ $n\in\mathbb{N}$ ។

បង្ហាញថា $\pi^2 I_n+n(n-1)I_{n-2}+n=0$ ចំពោះ $n\geq 2$ ។

រួចទាញបង្ហាញថា $\int_0^1 x^4\cos\pi x dx = \frac{4(6-\pi^2)}{\pi^4}$

សម្រាយបញ្ជាក់

១. យើងមាន $A+B+C=\pi \Rightarrow A+B=\pi-C$

យើងបាន $\cot(A+B)=\cot(\pi-C)=-\cot C \qquad (*)$

ដោយ $\tan(A+B)=\frac{\tan A+\tan B}{1-\tan A\tan B}$

$$\Rightarrow \cot(A+B)=\frac{1-\tan A\tan B}{\tan A+\tan B}=\frac{1-\frac{1}{\cot A\cot B}}{\frac{1}{\cot A}+\frac{1}{\cot B}}=\frac{\cot A\cot B-1}{\cot A+\cot B}$$

តាម $(*)$ $\Rightarrow \frac{\cot A\cot B-1}{\cot A+\cot B}=-\cot C$

$\Rightarrow \cot A\cot B-1=-\cot A\cot C-\cot B\cot C$

$\Rightarrow \cot A\cot B+\cot B\cot C+\cot A\cot C=1$

ដូច្នេះ $\cot A\cot B+\cot B\cot C+\cot A\cot C=1$

ទាញបង្ហាញថា $\tan A+\tan B+\tan C=\tan A\tan B\tan C$

យើងមាន $\cot A\cot B+\cot B\cot C+\cot A\cot C=1$

$$\Rightarrow \frac{1}{\tan A\tan B}+\frac{1}{\tan B\tan C}+\frac{1}{\tan A\tan C}=1$$

$$\Rightarrow \frac{\tan A+\tan B+\tan C}{\tan A\tan B\tan C}=1$$

ដូច្នេះ $\tan A+\tan B+\tan C=\tan A\tan B\tan C$

២. យើងមាន $x^z y = x + y^z$ (1)

$\Leftrightarrow x = x^z y - y^z$ (2)

តាម (1) x ចែកដាច់នឹង y ព្រោះ $x, y, z \in \mathbb{N}^*$

$\Rightarrow x^z$ ចែកដាច់នឹង y^z

តាម (2) $\Rightarrow x$ ចែកដាច់នឹង y^z $\Leftrightarrow x = ty^z$ ដែល $t \in \mathbb{N}^*$

តាម (2) $\Rightarrow t \cdot y^z = t^z \cdot y^{z^2} \cdot y - y^z$

$\Rightarrow t = t^z \cdot y^{z^2 - z + 1} - 1$

$\Rightarrow t + 1 = t^z \cdot y^{z^2 - z + 1}$ (3)

តាម (3) $\Rightarrow 1$ ចែកដាច់នឹង t $\Rightarrow t = 1$

$\Rightarrow y^{z^2 - z + 1} = 2$

ដោយ $y, z \in \mathbb{N}^*$ យើងបាន $y = 2$ និង $z^2 - z + 1 = 1$

នាំអោយ $y = 2,\ z = 1$

តាម (1) $\Rightarrow x = 2$

ដូច្នេះ $\{x, y, z\} = \{2, 2, 1\}$

៣. ឧបមា $x^2 \geq y^2 \geq z^2$ នោះ $x^2 \geq 3$ និង $6 \geq y^2 + z^2 \geq 2yz$

តាម វិសមភាព កូស៊ី ស្វាត

យើងបាន $\left[2(x+y+z) - xyz\right]^2 = \left[2(y+z) + x(2-yz)\right]^2$

$\leq \left[(y+z)^2 + x^2\right]\left[4 + (2-yz)^2\right] = (2yz+9)(y^2z^2 - 4yz + 8)$

តាង $a = yz$ នោះយើងគ្រាន់តែបង្ហាញថា

$(2a+9)(a^2 - 4a + 8) \leq 100$

$\Leftrightarrow 100-(2a+9)(a^2-4a+8)\ge 0$

$\Leftrightarrow 100-2a^3+8a^2-16a-9a^2+36a-72\ge 0$

$\Leftrightarrow -2a^3-a^2+20a+28\ge 0$

$\Leftrightarrow -2a^3+7a^2-8a^2+28a-8a+28\ge 0$

$\Leftrightarrow a^2(7-2a)+4a(7-2a)+4(7-2a)\ge 0$

$\Leftrightarrow (7-2a)(a^2+4a+4)\ge 0$

$\Leftrightarrow (a+2)^2(7-2a)\ge 0$ ពិត ព្រោះ $2a=2yz\le 6$

សមភាពកើតមានពេល $a=-2$

$\Rightarrow yz=-2$ និង $x^2=4(y+z)^2=20-4x^2$

$\Rightarrow x^2=4$ និង $y+z=\pm 1$ នាំអោយ $x=y=2$ និង $z=-1$

ដូច្នេះ $2(x+y+z)-xyz\le 10$

សញ្ញាស្មើកើតមានពេល $x=y=2$ និង $z=-1$

៤. ដោយ u,v,w ជាចំនួនកុំផ្លិច ដែលមាន ម៉ូឌុលស្មើ 1

តាង $u=e^{i\alpha};\ v=e^{i\beta}$ និង $w=e^{i\gamma}$

នាំអោយ $uv+vw+uw=e^{i(\alpha+\beta)}+e^{i(\beta+\gamma)}+e^{i(\alpha+\gamma)}$

$$=e^{i(\alpha+\beta+\gamma)}\left(e^{-i\gamma}+e^{-i\alpha}+e^{-i\beta}\right)$$

$$=e^{i(\alpha+\beta+\gamma)}\left(\overline{w}+\overline{u}+\overline{v}\right)$$

$$=e^{i(\alpha+\beta+\gamma)}\left(\overline{u+v+w}\right)$$

$\Rightarrow |uv+vw+uw|=\left|e^{i(\alpha+\beta+\gamma)}\left(\overline{u+v+w}\right)\right|=\left|e^{i(\alpha+\beta+\gamma)}\right|\left|\overline{u+v+w}\right|$

ដោយ $\left|e^{i(\alpha+\beta+\gamma)}\right|=1$ និង $\left|\overline{u+v+w}\right|=|u+v+w|$

ដូច្នេះ $|uv+vw+uw|=|u+v+w|$

៥. គណនា តួទូទៅនៃស្ទីត

ក. $\{a_n\}=\{1,3,10,22,39,...\}$

តាង $c_n=a_n-a_{n-1}$ ដែល $n\in\mathbb{N}^*$

យើងបាន $\sum_{i=1}^{n}c_i=a_n-a_0 \quad \Rightarrow a_n=\sum_{i=1}^{n}c_i+a_0$

ម្យ៉ាងទៀត យើងបាន $\{c_n\}=\{2,7,12,17,...\}$ ជាស្ទីតនព្វន្តដែល មានតួទីមួយ $c_1=2$ និង ផលសងរួម $d=5$

$$\Rightarrow\sum_{i=1}^{n}c_i=\frac{n\left(2c_1+(n-1)d\right)}{2}=\frac{n\left(4+(n-1)5\right)}{2}=\frac{5n^2-n}{2}$$

នាំអោយ $a_n=\frac{5n^2-n}{2}+1=\frac{5n^2-n+2}{2}$

ដូច្នេះ $a_n=\frac{5n^2-n+2}{2}$

ខ. $\{b_n\}=\{1,4,13,40,121,...\}$

តាង $d_n=b_n-b_{n-1}$ ដែល $n\in\mathbb{N}^*$

យើងបាន $\sum_{i=1}^{n}d_i=b_n-b_0 \quad \Rightarrow b_n=\sum_{i=1}^{n}b_i+b_0$

ម្យ៉ាងទៀត $\{d_n\}=\{3,9,27,81,...\}$ ជាស្ទីតធរណីមាត្រ ដែល មាន តួទីមួយ $d_1=3$ និង រេសុង $r=3$

$$\Rightarrow \sum_{i=1}^{n} d_i = d_1 \cdot \frac{1-r^n}{1-r} = 3\cdot\frac{1-3^n}{1-3} = \frac{3^{n+1}-3}{2}$$

នាំអោយ $b_n = \frac{3^{n+1}-3}{2} + 1 = \frac{3^{n+1}-1}{2}$

<u>ដូច្នេះ</u> $b_n = \frac{3^{n+1}-1}{2}$

៦. យើងមាន $I_n = \int_0^1 x^n \cos \pi x dx$

តាង $u = x^n \quad \Rightarrow du = nx^{n-1}dx$

$$dv = \cos \pi x dx \quad \Rightarrow v = \int \cos \pi x dx = \frac{1}{\pi}\sin \pi x$$

យើងបាន $I_n = \left(\frac{x^n}{\pi}\sin \pi x\right)\Bigg|_0^1 - \frac{n}{\pi}\int_0^1 x^{n-1}\sin \pi x dx$

$$\Rightarrow I_n = -\frac{n}{\pi}\int_0^1 x^{n-1}\sin \pi x dx \qquad (*)$$

ចំពោះ $\int_0^1 x^{n-1}\sin \pi x dx$

តាង $a = x^{n-1} \quad \Rightarrow da = (n-1)x^{n-2}dx$

$$db = \sin \pi x dx \quad \Rightarrow b = \int \sin \pi x dx = -\frac{1}{\pi}\cos \pi x$$

$$\Rightarrow \int_0^1 x^{n-1}\sin \pi x dx = \left(-\frac{x^{n-1}}{\pi}\cos \pi x\right)\Bigg|_0^1 - \int_0^1 \left(-\frac{1}{\pi}\cos \pi x\right)(n-1)x^{n-2}dx$$

$$\Rightarrow \int_0^1 x^{n-1}\sin \pi x dx = \frac{1}{\pi} + \frac{n-1}{\pi}\int_0^1 \left(x^{n-2}\cos \pi x\right)dx = \frac{1}{\pi} + \frac{n-1}{\pi} I_{n-2}$$

ជំនួសចូលក្នុង $(*)$ នាំអោយ

$$I_n = -\frac{n}{\pi}\left(\frac{1}{\pi} + \frac{n-1}{\pi} I_{n-2}\right) = -\frac{n}{\pi^2} - \frac{n(n-1)}{\pi^2} I_{n-2}$$

$$\Rightarrow \pi^2 I_n + n(n-1) I_{n-2} + n = 0$$

<u>ដូច្នេះ</u> $\pi^2 I_n + n(n-1) I_{n-2} + n = 0$

ទាញបង្ហាញថា $\int_0^1 x^4 \cos \pi x dx = \frac{4(6-\pi^2)}{\pi^4}$

តាមសម្រាយខាងលើ យើងបាន $\pi^2 I_4 + 4(4-1) I_2 + 4 = 0$

$$\Rightarrow I_4 = \frac{-12 I_2 - 4}{\pi^2}$$

ម្យ៉ាងទៀត $\pi^2 I_2 + 2(2-1) I_0 + 2 = 0$

$$\Rightarrow I_2 = \frac{-2 I_0 - 2}{\pi^2}$$ ដោយ $I_0 = \int_0^1 \cos \pi x dx \pi = \frac{1}{\pi}\sin \pi x\Big|_0^1 = 0$

$$\Rightarrow I_2 = -\frac{2}{\pi^2}$$

$$\Rightarrow I_4 = \int_0^1 x^4 \cos \pi x dx = \frac{-12\left(\frac{-2}{\pi^2}\right) - 4}{\pi^2} = \frac{-4\pi^2 + 24}{\pi^4} = \frac{4(6-\pi^2)}{\pi^4}$$

<u>ដូច្នេះ</u> $\int_0^1 x^4 \cos \pi x dx = \frac{4(6-\pi^2)}{\pi^4}$

វិញ្ញាសាទី៧

១. គេអោយស្វ៊ីត $0 \le a_1 \le a_2 \le \cdots \le a_{2011} < 1$ ។
ចូរប្រៀបធៀប $\log_{1/2010}\left(a_1 + a_2 + \cdots + a_{2010}\right)$ និង
$\log_{1/2011}\left(a_1 + a_2 + \cdots + a_{2011}\right)$

២. គណនាតំលៃអតិបរមា និង អប្បបរមានៃអនុគមន៍

$$f\left(x\right) = \frac{3 + 8x^2 + 12x^4}{\left(1 + 2x^2\right)^2}$$

៣. ដោះស្រាយសមីការៈ

ក. $P_x A_x^2 + 72 = 6\left(A_x^2 + 2P_x\right)$

ខ. $C_{n-1}^4 - C_{n-1}^3 - \frac{5}{4}A_{n-2}^2 = 0$

៤. បង្ហាញថា $A = \frac{1}{\cos^n \frac{\pi}{7}} + \frac{1}{\cos^n \frac{3\pi}{7}} + \frac{1}{\cos^n \frac{5\pi}{7}}$ ជាចំនួនសនិទាន ចំពោះគ្រប់ $n \in \mathbb{N}$ ។

៥. គេអោយ a,b,c ជាប្រវែងជ្រុងទាំងបីនៃត្រីកោណ និង p ជាកន្លះបរិមាត្រ។
បង្ហាញថា $\sqrt{p} < \sqrt{p-a} + \sqrt{p-b} + \sqrt{p-c} \le \sqrt{3p}$

៦. គណនាតួទី n នៃស្វីតដែលគោរពលក្ខខណ្ឌៈ $U_0 = \sqrt{2}$; $U_1 = \sqrt{3}$ និង $U_{n+2} - 5U_{n+1} + 6U_n = 0$ ។

សម្រាយបញ្ជាក់

១. យើងមាន $0 \le a_1 \le a_2 \le \cdots \le a_{2011} < 1$

$$\Rightarrow a_1 + a_2 + \cdots + a_{2010} \le 2010a_{2010} \le 2010a_{2011}$$

បូកអង្គទាំងពីរនៃវិសមភាពនឹង $2010(a_1 + a_2 + \cdots + a_{2010})$

$$\Rightarrow 2011(a_1 + a_2 + \cdots + a_{2010}) \le 2010(a_1 + a_2 + \cdots + a_{2011})$$

